**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៤៦១ ......សហវ.ប្រក.ពដ.

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៨១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១០


Collection by VCAT Professional Consultant

## សម្រេច :

**ប្រការ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១០ ត្រូវប្រមូលចាប់ពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១០ រហូតដល់ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១០ ។

**ប្រការ២.-** ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១០ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ (លើកលែងតែម្ចាស់ទោចក្រយានយន្ត) ព្រមទាំងបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ច នូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៩ ដើម្បីជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០០៩ រួចហើយ ។

**ប្រការ៣.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណា ពុំមានបង្កាន់ដៃពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ២០០៩ ទេនោះ ត្រូវបង់ប្រាក់ពន្ធសំរាប់ឆ្នាំ២០០៩ និងត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១០ ។

**ប្រការ៤.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសំរាប់ឆ្នាំ២០០៩ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសំរាប់ឆ្នាំ២០០៩ រួចហើយ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ នៃទីកន្លែងដែលបានបង់ពន្ធសំរាប់ឆ្នាំ២០០៩ ។

**ប្រការ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយ ទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

**ប្រការ៦.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះនេះ ត្រូវបានលើកលែងចំពោះ :

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ របស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**ប្រការ៧.-** ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងប័ណ្ណសំគាល់មួយសន្លឹក សំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ នោះ ។

បង្កាន់ដៃបង់ពន្ធនេះមានបិទក្រដាសពណ៌ទឹកប្រាក់មាន Bar code សំរាប់ត្រួតពិនិត្យពត៌មានរបស់យានយន្ត រចនាដោយអក្សរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរូបហង្សត្រួតពីលើ ដែលមានបោះពុម្ពលេខដែលតំណាងអោយចំនួនប្រាក់ពន្ធនៅផ្នែកខាងក្រោមប័ណ្ណនីមួយៗ។ បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យ ដែលមានសមត្ថកិច្ច និងទុកជាឯកសារសំរាប់បង់ពន្ធឆ្នាំ២០១១ ។

**ប្រការ៨.** សំរាប់ឆ្នាំ២០១០ ប័ណ្ណសំគាល់ដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ មានរូបភាព និងលក្ខណៈសំគាល់ដូចខាងក្រោម :

**១.ប័ណ្ណរាងចតុកោណស្មើជ្រុង :**

នៅខាងលើផ្នែកខាងឆ្វេងនៃប័ណ្ណមានអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**"និង"**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**"។ ខាងលើផ្នែកខាងស្តាំមានលេខ"**២០១០**" ។ ផ្នែកខាងឆ្វេងកណ្តាលមានបោះពុម្ព Bar code ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់ប័ណ្ណនីមួយៗ និងនៅចំកណ្តាលបោះពុម្ព Hologram ពណ៌ទឹកប្រាក់បង្កប់ និមិ្មតសញ្ញារូបហង្ស លេខ"**២០១០**" អក្សរ "**ប័ណ្ណបង់ពន្ធរថយន្ត**" និងទឹកប្រាក់ពន្ធតាមប្រភេទប័ណ្ណ ព្រមទាំងមានកំរងក្បូរស្រូវទ្រពីក្រោមតាមរចនាបថអង្គរ។ ផ្នែកខាងក្រោមមានអក្សរ "**ប័ណ្ណបង់ពន្ធរថយន្ត**" ឬ"**ប័ណ្ណបង់ពន្ធត្រាក់ទ័រ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងមានចំនួនទឹកប្រាក់ពន្ធ។ នៅផ្នែកខាងស្តាំមានរូបហង្ស អក្សរ"**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" និង "**អគ្គនាយកដ្ឋានពន្ធដារ**" ។ នៅផ្នែកខាងក្រោយនៃសន្លឹកប័ណ្ណមានបង្កប់បន្ទះឈីប(Chip) (លើកលែងប័ណ្ណបង់ពន្ធត្រាក់ទ័រ) សំរាប់ការពារការក្លែងបន្លំប័ណ្ណ។

ប័ណ្ណរាងចតុកោណស្មើជ្រុងនេះ មាន**១៣**ពណ៌គឺ :

- **ប័ណ្ណពណ៌ខៀវខ្ចី ប្រើសំរាប់ :**
  - + ត្រាក់ទ័រមានកម្លាំង ៣៥ សេះ **(៣០.០០០រៀល)**
  - + ត្រាក់ទ័រមានកម្លាំង ៦៥ សេះ **(៤០.០០០រៀល)**
  - + ត្រាក់ទ័រមានកម្លាំង ៨២ សេះ **(៥០.០០០រៀល)**
- **ប័ណ្ណពណ៌ត្រួយចេក(៨០.០០០រៀល) ប្រើសំរាប់ :**
  - + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ
- **ប័ណ្ណពណ៌ក្រហម(១០០.០០០រៀល) ប្រើសំរាប់ :**
  - + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
  - + រថយន្តទេសចរណ៍កម្លាំងលើសពី១៥០០ ស.ម³ដល់២០០០ស.ម³ គិតពីឆ្នាំផលិតលើស៥ឆ្នាំ
- **ប័ណ្ណពណ៌ផ្កាឈូក (១៥០.០០០រៀល) ប្រើសំរាប់ :**
  - + រថយន្តដឹកទំនិញដល់ ៣ តោន
  - + រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  - +រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី១៥០០ស.ម³ដល់២០០០ស.ម³គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- **ប័ណ្ណពណ៌លឿងទុំ(២០០.០០០រៀល) ប្រើសំរាប់ :**

+ រថយន្តដឹកអ្នកដំណើរធុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី

- **ប័ណ្ណពណ៌លឿងខ្ចី (២៥០.០០០រៀល)ប្រើសំរាប់ :**

  + រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន

  + រ៉ឺម៉កសណ្តោង ដល់ ១០ តោន

  + រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥

- **ប័ណ្ណពណ៌ទឹកប៊ិច(៤៥០.០០០រៀល) ប្រើសំរាប់ :**

  + រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន

  + រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន

- **ប័ណ្ណពណ៌បៃតង និងពណ៌ត្រួយចេក(៧៥០.០០០រៀល) ប្រើសំរាប់ :**

  + រថយន្តដឹកទំនិញលើសពី ២០ តោន

  + រ៉ឺម៉កសណ្តោងលើសពី ២០ តោន

- **ប័ណ្ណពណ៌បៃតង(៣៦០.០០០រៀល) ប្រើសំរាប់ :**

  +រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី២០០០ស.ម$^3$ដល់ ២៩០០ស.ម$^3$ គិតពីឆ្នាំផលិតលើសពី៥ឆ្នាំ

- **ប័ណ្ណពណ៌លឿងនិងពណ៌ផ្កាឈូក(៥០០.០០០រៀល) ប្រើសំរាប់ :**

  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២០០០ ស.ម$^3$ ដល់ ២៩០០ ស.ម$^3$ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ

- **ប័ណ្ណពណ៌ខៀវខ្ចី និងពណ៌ផ្ទៃមេឃ(១.២០០.០០០រៀល) ប្រើសំរាប់ :**

  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម$^3$ ដល់ ៤០០០ ស.ម$^3$ គិតពីឆ្នាំផលិតលើស ៥ឆ្នាំ

- **ប័ណ្ណពណ៌ក្រហម និងពណ៌លឿងខ្ចី (១.៦០០.០០០រៀល)ប្រើសំរាប់ :**

  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម$^3$ ដល់ ៤០០០ ស.ម$^3$ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ

- **ប័ណ្ណពណ៌ស្វាយ និងពណ៌លឿងទុំ (២.០០០.០០០រៀល)ប្រើសំរាប់ :**

  + រថយន្តទេសចរណ៍កម្លាំងលើសពី ៤០០០ ស.ម$^3$ ឡើងទៅ

## ២. ប័ណ្ណរាងចតុកោណកែង :

នៅខាងលើផ្នែកខាងឆ្វេងនៃប័ណ្ណមានអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" និងអក្សរ "**អគ្គនាយកដ្ឋានពន្ធដារ**" ខាងលើផ្នែកខាងស្តាំមានលេខ"២០១០" ។ ផ្នែកខាងឆ្វេងកណ្តាលមានបោះពុម្ព Bar code ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់ប័ណ្ណនីមួយៗ និង Hologram នៅកណ្តាលប័ណ្ណដែលមានបង្កប់ លេខ"២០១០" អក្សរ "**ប័ណ្ណបង់ពន្ធលើយានយន្ត**" ។ ផ្នែកខាងក្រោមមានអក្សរ "**ប័ណ្ណបង់ពន្ធលើយានយន្ត**" និងចំនួនប្រាក់ពន្ធនៃប័ណ្ណនៅខាងក្រោម ។

បណ្ណរាងចតុកោណកែងនេះ មាន៤ពណ៌គឺ :

- **បណ្ណពណ៌បៃតង (៣.០០០រៀល) ប្រើសំរាប់ :**

  + ទោចក្រយានយន្តទំហំពិសស្តុង ដល់ ៧០ សម[៣]

- **បណ្ណពណ៌ផ្កាឈូក (៤.៥០០រៀល) ប្រើសំរាប់ :**

  + ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ៧០ សម[៣] ទៅ ១២៥ សម[៣]

- **បណ្ណពណ៌ខៀវខ្ចី (៧.៥០០រៀល) ប្រើសំរាប់ :**

  + ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ១២៥ សម[៣] ឡើងទៅ ដែលមានទឹកប្រាក់ពន្ធចំនួន ៧,៥០០ រៀល

- **បណ្ណពណ៌លឿងខ្ចី (១៥.០០០រៀល) ប្រើសំរាប់ :**

  + ត្រីចក្រយានយន្ត និងម៉ូតូរ៉ឺម៉កដឹកទំនិញ ឬអ្នកដំណើរ (បំពាក់ដោយម៉ាស៊ីនម៉ូតូ)ដែលមានទឹកប្រាក់ពន្ធ ចំនួន ១៥,០០០ រៀល

## ៣. បណ្ណរាងចតុកោណព្នាយ:

នៅផ្នែកខាងលើនៃប័ណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" និងលេខ "២០១០" ផ្នែកកណ្តាលមានបោះពុម្ព Hologram ផ្នែកខាងក្រោមមានអក្សរ "**បណ្ណបង់ពន្ធជលយាន**" "**អគ្គនាយកដ្ឋានពន្ធដារ**" Bar code និង លេខរៀងពាំខ្ទង់នៃប័ណ្ណនីមួយៗ។

បណ្ណរាងចតុកោណព្នាយនេះ មាន៣ពណ៌គឺ :

- **បណ្ណពណ៌បៃតង ប្រើសំរាប់ :**

  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០៛ ដល់ ៧០.០០០៛

- **បណ្ណពណ៌ផ្កាឈូក ប្រើសំរាប់ :**

  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០៛ ដល់ ៥០០.០០០៛

- **បណ្ណពណ៌លឿងទុំ ប្រើសំរាប់ :**

  + ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០៛ ដល់ ១.២០០.០០០៛

**ប្រការ៩.-** ដោយឡែក សំរាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះរថយន្តដឹកទំនិញ និងរ៉ឺម៉ក-សណ្តោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុប ដែលរួមមានទម្ងន់រថយន្តទទេ និងទម្ងន់ផ្ទុក (ទំនិញ-មនុស្ស) ។

- ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត និង រថយន្តកែច្នៃកង់បី ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០,០០០៛ ។
- រឺងរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០,០០០៛ ។
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០,០០០៛ ។
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០,០០០៛ ។

- និងរ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០,០០០៛ ។

**ប្រការ១០.-** យានយន្តគ្រប់ប្រភេទ ដែលមានប័ណ្ណសំគាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៩ ហើយបានលក់ទៅឱ្យអ្នកផ្សេង ក្នុងករណីនេះត្រូវកំណត់អោយបង់ពន្ធសំរាប់ឆ្នាំ២០០៩ និងបង់ប្រាក់ពិន័យស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធសំរាប់ឆ្នាំ២០១០ ។

**ប្រការ១១.-** មធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសកម្មរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមកបំពេញលិខិតប្រកាសតាមគំរូដោយឡែកមួយ និងបង់ពន្ធនៅអង្គភាពពន្ធដារដែលសហគ្រាសនោះប្រកាសបង់ពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម... ជារៀងរាល់ខែ ។

**ប្រការ១២.-** ចាប់ពីថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១០ នេះតទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណាដែលមិនបានបង់ពន្ធសំរាប់ឆ្នាំ២០១០ ដូចបានកំណត់ក្នុងប្រការ១ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់អោយធ្វើចរាចរនៅក្រោយថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១០ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់អមដោយបង្កាន់ដៃបង់ពន្ធនាំចូល ឬប័ណ្ណសំគាល់យានយន្តថតចំលង... ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ២០១០ នេះ ។

**ប្រការ១៣.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

***កន្លែងទទួល :***

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ